មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា
Cambodian Center for Human Rights



# តើអ្វីជាអំពើហិង្សាទាក់ទងនឹងយេនឌ័រ?

# What is Gender-Based violence?

អំពើហិង្សាទាក់ទងនឹងយេនឌ័រសំដៅរាល់ទង្វើដែលបង្កគ្រោះថ្នាក់ មិនថាគ្រោះថ្នាក់រូបរាងកាយ ផ្លូវភេទ ផ្លូវចិត្ត ឬសេដ្ឋកិច្ច ដោយផ្ទាល់ទៅលើស្ត្រី និងក្មេងស្រី ដោយសារតែយេនឌ័ររបស់ពួកគេ។ អំពើហិង្សាទាក់ទងនឹងយេនឌ័រនេះ កើតចេញមកពីវិសមភាពយេនឌ័រ ការរំលោភអំណាច និងផ្នត់គំនិតអវិជ្ជមាននានាដែលបង្កគ្រោះថ្នាក់។

**Gender-based violence (“GBV”) refers to harmful acts, whether physical, sexual, psychological, or economic, directed against an individual based on gender, predominantly against women and girls. It  stems from gender inequality, abuse of power, and harmful gender norms.**



CC BY NC SA

៨ មីនា ២០២៣ / 8 March 2023

មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា
Cambodian Center for Human Rights



ជនរងគ្រោះដោយអំពើហិង្សាទាក់ទងនឹងយេនឌ័រមិនអាច
ចែករំលែកព័ត៌មានជាក់ស្តែងនៅពេលដំណើការក្តី ដើម្បី
ស្វែងរកយុត្តិធម៌បានឡើយ ប្រសិនបើពួកគាត់មិនទទួល
បានការគិតគូរ និងការយកចិត្តដាក់អំពីតម្រូវការ
ផ្អែកលើយេនឌ័ររបស់ពួកគាត់។ ដូចនេះពួកគាត់ប្រឈម
នឹងការបាត់បង់យុត្តិធម៌។



**The lack of gender sensitivity in the justice system and support services prevents victims of gender-based violence from reporting abuses and seek justice.**



BY NC SA

៨ មីនា ២០២៣/ 8 March 2023

មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា
Cambodian Center for Human Rights

# អំពើហិង្សាទាក់ទងនឹងយេនឌ័រជាតួលេខ

## GBV IN NUMBERS

### ទូទាំងពិភពលោក
### WORLDWIDE

ស្ត្រី ១ នាក់ ក្នុងចំណោម ៣ នាក់ ទទួលរងអំពើហិង្សាលើរូបរាងកាយ ឬផ្លូវចិត្ត ពីសំណាក់ដៃគូរបស់ខ្លួន។

1 in 3 women has reported experiencing physical or sexual violence at the hands of their partner.

### នៅកម្ពុជា
### CAMBODIA

ស្ត្រី ១ នាក់ ក្នុងចំណោមស្ត្រី ៥ នាក់ ដែលមានអាយុចន្លោះពី១៥-៤៩ ឆ្នាំ ទទួលរងអំពើហិង្សាពីសំណាក់ដៃគូស្និទ្ធស្នាលរបស់ខ្លួន។

1 in 5 women aged between 15 and 49 have reported experiencing physical violence

CC BY NC SA

៨ មីនា ២០២៣ / 8 March 2023

មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា
Cambodian Center for Human Rights



# អំពើហិង្សាទាក់ទងនឹងយេនឌ័រនៅកម្ពុជា
# GBV IN CAMBODIA

អំពើហិង្សាទាក់ទងនឹងយេនឌ័រនៅតែបន្តកើតមាននៅទូទាំងប្រទេស។ ក្នុងនោះមានស្ត្រី ២ នាក់ ក្នុងចំណោមស្ត្រី ១០ នាក់ មានអាយុចន្លោះពី ១៥-៤៩ ឆ្នាំ ទទួលរងអំពើហិង្សាលើរូបរាងកាយ តាំងពីពួកគេមានអាយុ ១៥ ឆ្នាំ។ ជាទូទៅចំនួន ៦% នៃស្ត្រីកម្ពុជា អាយុចន្លោះពី ១៥-៤៩ ឆ្នាំ ទទួលរងអំពើហិង្សាផ្លូវភេទ។

Gender-based violence (GBV) remains pervasive across the country. Two in ten Cambodian women aged between 15 and 49 have experienced physical violence at least once since the age of 15. Overall, 6% of Cambodian women aged between 15 and 49 years old have experienced sexual violence at least once.



ផ្នត់គំនិតរើសអើងតួនាទីយេនឌ័រក្នុងសង្គម និងក្នុងគ្រួសារគឺជាឫសគល់នាំឱ្យមានវិសមភាពយេនឌ័រ ដែលជាបុព្វហេតុនាំឱ្យកើតមានការរំលោភបំពានសិទ្ធិ។ សកម្មភាពហិង្សាលើស្ត្រីកើតឡើងដូចជា តួនាទីយេនឌ័រដែលត្រូវបានកំណត់ ឬផ្នត់គំនិតដែលស្ត្រីត្រូវស្តាប់បង្គាប់។ បញ្ហានេះជំរុញឱ្យមានអំពើហិង្សាទាក់ទងនឹងយេនឌ័រក្នុងដំណើរនៃជីវិត ដូចជា នៅក្នុងផ្ទះ សហគមន៍ ឬនៅកន្លែងការងារ។ បន្ថែមលើនេះ អំពើហិង្សាទាក់ទងនឹងយេនឌ័រអាចត្រូវបានប្រព្រឹត្តពីសំណាក់ដៃគូ សមាជិកគ្រួសារ សហការី អ្នកស្គាល់គ្នា ឬមន្ត្រីសាធារណៈ ឬអ្នកផ្សេងទៀត។

Entrenched gender stereotypes and norms contribute to gender inequality and women's rights abuses in Cambodia. Prescribed gender roles, and the principle of female submissiveness, they promote, nurture GBV in all walks of life - in the home, in the community, or the workplace. In addition, GBV can be perpetrated by partners, family members, colleagues, acquaintances, or public officials or more.



ប្រភព៖ ការរកឃើញសំខាន់ៗ នៃរបាយការណ៍អង្កេតប្រជាសាស្ត្រ និងសុខភាពកម្ពុជា ឆ្នាំ២០១៤

Source: 2014 Demographic and Health Survey Key Findings

CC BY NC SA

៨ មីនា ២០២៣ / 8 March 2023



មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា
Cambodian Center for Human Rights

"ប្រជាពលរដ្ឋទាំងអស់មានសិទ្ធិស្មើគ្នាចំពោះមុខច្បាប់
និងទទួលបានសិទ្ធិ និងសេរីភាពដូចគ្នាទាំងអស់
ដោយមិនមានការរើសអើង...

All citizens are equal before the law and
enjoy the same rights and freedoms
without discrimination of any kind..."

មាត្រា៣១ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
Article 31 of Constitution of Cambodia





CC BY NC SA

៨ មីនា ២០២៣ / 8 March 2023

មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា
Cambodian Center for Human Rights



អំពើជួញដូរមនុស្ស ការធ្វើអាជីវកម្មផ្លូវភេទ និងអំពើអាស
អាភាស គឺជាអំពើខុសច្បាប់ជាតិ និងអន្តរជាតិ

**Human trafficking, sexual exploitation, and child pornography are illegal acts prohibited under both domestic and international law.**







CC BY NC SA

៨ មីនា ២០២៣ / 8 March 2023